o សោហ៊ុយចំណោយសំរាប់កម្មវិធីថ្នាក់ជាតិ

បទពិសោធន៍ជាច្រើនបានបង្ហាញថា ឧស្សាហកម្មដាំឈើជាទ្រង់ទ្រាយធំ បានញែកប្រជាជនចេញពីព្រៃឈើ ការដាំឈើតែមួយប្រភេទត្រូវប្រឈមនឹងការគំរាមកំហែងខ្លាំង ទាមទារឱ្យមានការចំណាយខ្ពស់ ប៉ុន្តែផ្តល់នូវលទ្ធភាពប្រើប្រាស់តិចតួចសំរាប់សហគមន៍មូលដ្ឋាន ក៏ដូចជាផ្តល់សេវាកម្មតិចតួចខាងផ្នែកបរិស្ថាន ហើយកម្មវិធីដាំឈើរបៀបនេះ ក៏មានការចូលរួមតិចតួចពីប្រជាជនមូលដ្ឋាន។ ដោយងាកចេញពីឧស្សាហកម្មដាំឈើជាទ្រង់ទ្រាយធំ ជម្រើសនៃការដាំឈើដោយសហគមន៍ និង ការដាំឈើនៅលើដីចំការឯកជន ត្រូវបានប្រកាន់យកដើម្បីបំពេញឱ្យបានជាអតិបរមានូវតម្រូវការសង្គមនិងទីផ្សារសំរាប់ផលិតផលឈើ។

ដូច្នេះ ដើម្បីជ្រើសរើសទីតាំងនិងគ្រប់គ្រងការងារដាំឈើឱ្យបានជោគជ័យ ទាមទារជាបឋមឱ្យមានការសិក្សាអំពីកត្តាសង្គម សេដ្ឋកិច្ច នយោបាយ និងបរិស្ថាន ដើម្បីឱ្យកម្មវិធីដាំឈើនេះទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។

## ៤. ក្នុងបរិបទនៃប្រទេសកម្ពុជា

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការគ្រប់គ្រងព្រៃឈើបានផ្តោតជាសំខាន់លើការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរយៈការផ្តល់ឱ្យនូវសម្បទានដីព្រៃដែលមានទំហំធំៗទៅដល់វិនិយោគិនដែលភាគច្រើនជាជនបរទេស។ ការប្រកាន់យកនូវជំរើសបែបនេះ មិនទទួលបានជោគជ័យទេ ដោយសារគេបានជន្លៀសប្រជាជនចេញក្រៅហើយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការធ្វើអាជីវកម្មឈើជាជាងការអនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ បណ្តាព្រៃសម្បទានទាំងអស់ត្រូវបានផ្អាកនៅដើមឆ្នាំ ២០០១ ដើម្បីរង់ចាំការកសាង និង សំរេចលើផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ហើយជាផលវិបាកការផ្អាកនេះបាននាំទៅដល់ការគ្មានការគ្រប់គ្រងជាផ្លូវការចំពោះដែនព្រៃឈើមួយចំនួនធំ ភាពគ្មានសិទ្ធិច្បាស់លាស់ក្នុងការគ្រប់គ្រង ហើយចុងបញ្ចប់ឈានដល់ការធ្វើអាជីវកម្មដោយអាណាធិបតេយ្យ។ គោលនយោបាយនៃវិស័យព្រៃឈើក្នុងពេលបច្ចុប្បន្ននេះបានងាកទៅរកការអភិរក្ស និងការស្តារដីព្រៃរេចរិលឡើងវិញតាមរយៈការចូលរួមពីភាគីពាក់ព័ន្ធនានា។ ការតំរង់ទិសទៅរកជំរើសមួយដែលយកប្រជាជនជាគោលដៅប ានផ្តល់នូវកាលានុវត្តភាពមួយយ៉ាងសំខាន់សំរាប់វិស័យព្រៃឈើក្នុងការបង្កើននូវតួនាទីរបស់ខ្លួន សំដៅសំរេចឱ្យបាននូវកម្មវត្ថុនៃការអភិវឌ្ឍន៍ជាតិ ការចូលរួមដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងការរគប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

## ៤.១ មូលហេតុនៃភាពរេចរិលនិងបាត់បង់ព្រៃឈើ

មូលហេតុនៃភាពរេចរិលនិងការបាត់បង់ព្រៃឈើនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ដោយ សមាគមន៍ក្នុងកិច្ចអភិវឌ្ឍន៍ជនបទ (ARD, 1998a) ថាបណ្តាលមកពីភាពក្រីក្រគោកយ៉ាកនៅជនបទ កង្វះខាតដីកសិកម្ម ការផ្តល់សិទ្ធឱ្យប្រើប្រាស់ដីច្រើនហួសហេតុ កង្វះខាតការថវិកាសំរាប់ការអភិវឌ្ឍន៍និងថវិកាសំរាប់ផ្នែករដ្ឋបាល និងសមត្ថភាពស្ថាប័ននៅមានកំរិត ហើយមូលហេតុទាំងនេះបង្ហាញឱ្យឃើញតាមរយៈសកម្មភាពនានាដូចជា ការកាប់ឈើដោយអានាធិបតេយ្យ ការរុករានទន្រ្ទានដីព្រៃឈើ ការវាតដីព្រៃដើម្បីធ្វើកសិកម្ម ភ្លើងឆេះព្រៃ ការចាប់ដីព្រៃឈើធ្វើជាកម្មសិទ្ធិនិងសំរាប់លក់យកចំណេញ។ ដូច្នេះគេត្រូវពិចារណាលើរាល់បញ្ហាទាំងអស់នេះឱ្យបានហ្មតចត់ ក្នុងការធ្វើផែនការដើម្បីដាំឈើ និងស្តារព្រៃឈើឡើងវិញ ដើម្បីធានាឱ្យការងារនេះទទួលបានជោគជ័យ។

លើសពីនេះទៀត ដែនព្រៃឈើធំៗបាននឹងកំពុងត្រូវបានបង្វែរទីសប្រើប្រាស់សំរាប់គោលបំណងផ្សេងទៀតវិញ តាមរយៈ សម្បទានសេដ្ឋកិច្ចទៅឱ្យឧស្សាហកម្មដាំឈើ ជាពិសេសសំរាប់ដំណាំកៅស៊ូ ឧស្សាហកម្មផលិតម្សៅក្រដាស និង ដំណាំ ដូងប្រេង។

## ៤.២ បទពិសោធន៍ក្នុងការងារដាំដើមឈើ និង ការស្តារព្រៃឈើ

ចាប់តាំងពីឆ្នាំ ១៩៨៥ រហូតមកទល់នឹងឆ្នាំ ២០០២ រាជរដ្ឋាភិបាលបានវិនិយោគតិចតួចបំផុតក្នុងការងារដាំដើមឈើ គឺថាមានផ្ទៃដីសរុបទំហំ ១១ ១២៥ ហិកតាត្រូវបានដាំដុះដោយរដ្ឋបាលព្រៃឈើ (DFW, 2003)។ ក៏ប៉ុន្តែទោះបីជាគេមិនបានដឹងច្បាស់លាស់ក៏ដោយ គេជឿជាក់ថាសហគមន៍មូលដ្ឋានបានចូលរួមក្នុងការងារដាំដើមឈើយ៉ាងសកម្មផងដែរនៅក្នុងបរិវេណដែនព្រៃឈើដែលគ្រប់គ្រងដោយសហគមន៍ទំហំ ៦៤ ៩០១ ហិកតា(DFW, 2003) និងនៅក្នុងតំបន់ដែលពុំមានព្រៃឈើដូចជាទីធ្លាជុំវិញភូមិដ្ឋាន លើភ្លឺស្រែ និងនៅតាមទីសាធារណៈនានា។ រដ្ឋបាលព្រៃឈើបានចែកចាយកូនឈើដើម្បីគាំទ្រសកម្មភាពទាំងនេះ ក៏ប៉ុន្តែក្នុងរយៈពេលចុងក្រោយនេះ ក្រុមហ៊ុនឯកជនបានឈានមុខក្នុងការងារនេះទៅវិញ។ នេះសបញ្ជាក់ឱ្យឃើញថាក្រុមហ៊ុនឯកជន អ្នកដាំឈើតូចតាច និងសហគមន៍ប្រហែលជាអាចបំពេញតួនាទីបានយ៉ាងល្អប្រសើរក្នុងការងារដាំដើមឈើ ឯរដ្ឋាភិបាលគួរដើរតួនាទីជាអ្នកសំរបសំរួលដល់ការកាត់បន្ថយភាពក្រីក្រ ការបង្កើនជីវភាពរស់នៅប្រចាំថ្ងៃហើយភារកិច្ចដាំដើមឈើរបស់រដ្ឋ គួរផ្តោតលើផលប្រយោជន៍ខាងបរិស្ថានវិញប្រសើរជាងដូចជាការពារទីជំរាល និងការអភិរក្សធនធានសេនេទិកព្រៃឈើជាដើម។ បញ្ហាដែលគួរពិចារណារួមមាន:

- o គោលនយោបាយ កម្មវត្ថុនៃការប្រើប្រាស់ផលិតផលសំរេច និងយន្តការ
  - ការផ្លាស់ប្តូរបានផ្តោតលើការអភិរក្ស និងការស្តារដីព្រៃឈើឡើងវិញ ពីទីផ្សារអន្តរជាតិទៅទីផ្សារក្នុស្រុកនិងពីឧស្សាហកម្មដាំឈើជាទ្រង់ត្រាយធំទៅជាការដាំឈើជាទ្រង់ទ្រាយតូចតាច/ការដាំឈើចំរុះប្រភេទដោយសហគមន៍ ដែលជាការចូលរួមវិភាគទានក្នុងការកាត់បន្ថយភាពក្រីក្រ
- o ភាពដែលអាចរកបាននៃដីដាំឈើ
  - ទោះបីជាផ្ទៃដីដ៏ធំធេងហាក់ដូចជាសមស្របសំរាប់ការងារដាំដើមឈើ ប៉ុន្តែភាគច្រើននៃដីទាំងនេះសុទ្ធសឹងតែមានទំនាស់ក្នុងការប្រើប្រាស់ / ផលប្រយោជន៍
- o សិទ្ធិនៃការប្រើប្រាស់ដី ការកាន់កាប់ដី និង ភាពជាម្ចាស់លើដំណាំ
  - ការប្រកាន់យកនូវការចូលរួមក្នុងការរៀបចំធ្វើផែនការប្រើប្រាស់ដី និង ការធ្វើសេចក្តីសំរេចគឺជាបញ្ហាសំខាន់ដើម្បីធានាជោគជ័យក្នុងការងារដាំដើមឈើ
- o ការធ្វើផែនការ និងផែនការថវិកា
  - ទាមទារឱ្យមានជាចាំបាច់នូវផែនការរយៈពេលវែង ព្រមទាំងថវិកាត្រៀមគ្រប់គ្រាន់សំរាប់ការធ្វើលទ្ធកម្មគ្រាប់ពូជ និងការបង្កើតថ្នាលបណ្តុះកូនឈើ
- o ចំណេះដឹងផ្នែកបច្ចេកទេស ការសិក្សាស្រាវជ្រាវ និង ផ្សព្វផ្សាយ
  - ចំណុចសំខាន់សំរាប់ការងារដាំដើមឈើគឺការជ្រើសរើសទីតាំង ការជ្រើសរើសប្រភេទឈើឱ្យបានត្រូវនឹងទីតាំង និងទាន់ពេលវេលា និងការប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពល្អ
- o ធ្វើផែនការទីផ្សារសំរាប់ផលិតផលសំរេច
  - ការផ្តោតអារម្មណ៍ត្រូវបានផ្លាស់ប្តូរពីការផ្គត់ផ្គង់ឈើមូលនៅក្នុងទីផ្សារអន្តរជាតិទៅជាផលិតផលព្រៃឈើច្រើនប្រភេទសំរាប់ទីផ្សារក្នុងស្រុក និង អន្តរជាតិ ។

## ៤.៣ ការគាំទ្រដល់សកម្មភាពដាំដើមឈើ

ដំណើរការនៃការកែទំរង់វិស័យព្រៃឈើ ផ្តោតការយកចិត្តទុកដាក់លើការបង្កើនសកម្មភាពដាំដើមឈើដោយរដ្ឋបាល ព្រៃឈើ កងទ័ព និង សហគមន៍មូលដ្ឋាន តាមរយៈការអនុវត្តនូវច្បាប់ស្តីពីព្រៃឈើ (RGC, 2003) ។ គេបានប៉ាន់ប្រមាណថាមានផ្ទៃដីព្រៃរេចរិលចំនួនប្រហែល ៦ លានហិកតា ( ប្រហែលជា៦0%នៃផ្ទៃដីព្រៃឈើសរុប ) ដែលទាមទារឱ្យមានការស្តារព្រៃឈើឡើងវិញ (DFW, 2001) ទោះបីជានៅក្នុងទីវាលជាក់ស្តែងភាគច្រើននៃដីព្រៃ

ឈើទាំងនោះត្រូវបានកាន់កាប់ដោយសហគមន៍ ពាណិជ្ជករ និងពួកអ្នកមានអំណាចមួយចំនួនក្តី។ រដ្ឋបាលព្រៃឈើបាន កំណត់កម្មវត្ថុនៃការដាំដើមឈើចំនួនបីគឺដើម្បី ការកាត់បន្ថយភាពក្រីក្រ ការការពារបរិស្ថាន និងការអភិវឌ្ឍន៍ សេដ្ឋកិច្ច ដែលនេះជាការឆ្លុះបញ្ចាំងដោយផ្ទាល់ពីសេចក្តីថ្លែងការស្តីពីគោលនយោបាយវិស័យព្រៃឈើរបស់រាជរដ្ឋាភិបាល (2002) ដែលថា:

រាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ចំពោះការអភិរក្ស និងគ្រប់គ្រងធនធានព្រៃឈើដោយធានាភាពស្ថិតស្ថេរនៃអេកូឡូស៊ី សង្គម និង សេដ្ឋកិច្ច ដែលជាសរសរគ្រឹះមួយយ៉ាងសំខាន់សំរាប់សុខុមាលភាពសាធារណៈ និង ជាវិភាគទានដោយផ្ទាល់ចំពោះការការពារបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។

រដ្ឋបាលព្រៃឈើនឹងយកចិត្តទុកដាក់ជាពិសេស ចំពោះការជំនួសការផ្គត់ផ្គង់ឈើដោយព្រៃធម្មជាតិទៅជាការផ្គត់ផ្គង់ដោយចំការព្រៃដាំ តាមរយៈការលើកទឹកចិត្តឱ្យមានការវិនិយោគជាលក្ខណៈឯកជន និង ការចូលរួមពីសាធារណៈជនទូទៅ (DFW, 2002a)។ ផែនការដាំឈើរយៈពេលវែងត្រូវតែរៀបចំឡើង ដែលក្នុងនោះរដ្ឋបាលព្រៃឈើថ្នាក់កណ្តាលទទួលខុសត្រូវលើកិច្ចសហប្រតិបត្តិការជាអន្តរជាតិ និង កម្មវិធីដាំឈើជាទ្រង់ទ្រាយធំ ចំណែកឯរដ្ឋបាលព្រៃឈើនៅមូលដ្ឋាន ជំរុញ លើកទឹកចិត្តដល់ការដាំឈើជាទ្រង់ទ្រាយតូច និងការដាំឈើដោយសហគមន៍។

## ៥.ឧម្រង់នានានៃការងារដាំឈើ

ការអនុវត្តសកម្មភាពដាំដើមឈើ អាចនឹងទទួលបានជោគជ័យធំធេងនៅទីណាដែលការកាន់កាប់ដីត្រូវបានធានាក្នុងរយៈពេលយូរអង្វែង តម្រូវការរបស់មូលដ្ឋានត្រូវបានបំពេញ ហើយសេចក្តីសំរេចចិត្តត្រូវបានទទួលយកដោយសង្គមទាំងមូល (ITTO 1993)។ នៅក្នុង បរិបទនៃគោលការណ៍ណែនាំនេះ ការដាំដើមឈើអាចមានន័យថា (សូមមើលផ្នែកទី ២ អំពីគោលការណ៍ណែនាំបច្ចេកទេស):

- ការស្តារឡើងវិញនូវដីព្រៃរេចរិល និងព្រៃដុះឡើងវិញ
- សកម្មភាពដាំដើមឈើដោយសហគមន៍
- ការបង្កើតចំការឈើដាំជាទ្រង់ទ្រាយធំ
- ការដាំដើមឈើនៅលើដីចំការឯកជន